ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៣១០៧ សហវ.ប្រក

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការបែងចែកចំណូលពីសេវាសាធារណៈ និងចំណូលពីការពិន័យរបស់ក្រសួងពាណិជ្ជកម្ម

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៧ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញប្រកាសអន្តរក្រសួងលេខ៣១៥ សហវ.ប្រក ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញប្រកាសអន្តរក្រសួងលេខ៣១៦ សហវ.ប្រក ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១ ស្តីពីការពិន័យជាប្រាក់ដែលស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ .–**

ចំណូលពីសេវាសាធារណៈ ដែលប្រមូលបានដោយអង្គភាពរដ្ឋបាលកណ្តាលនៃក្រសួងពាណិជ្ជកម្ម លើប្រភេទសេវាស្ថិតក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសអន្តរក្រសួងលេខ៣១៥ សហវ.ប្រក ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១ ត្រូវបែងចែកដូចតទៅ ÷

| | | |
|---|---|---|
| - បង់ចូលថវិកាជាតិ | ចំនួន ៤០% | នៃចំណូលប្រមូលបាន |
| - ប្រាក់រង្វាន់របស់ក្រសួងពាណិជ្ជកម្ម | ចំនួន ៥៨% | នៃចំណូលប្រមូលបាន |
| - ប្រាក់រង្វាន់បង់ចូលមូលនិធិ ក.ហ.ស | ចំនួន ១% | នៃចំណូលប្រមូលបាន |
| - ប្រាក់រង្វាន់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ចំនួន ១% | នៃចំណូលប្រមូលបាន។ |

**ប្រការ២ .–**

ចំណូលពីសេវាសាធារណៈ ដែលក្រសួងពាណិជ្ជកម្មធ្វើប្រតិភូកម្មមុខងារជូនរដ្ឋបាលរាជធានី ខេត្ត លើប្រភេទសេវាដែលចែងក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសអន្តរក្រសួងលេខ៣១៥ សហវ.ប្រក ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១ បែងចែកដូចខាងក្រោម ÷

- បង់ចូលថវិការបស់រដ្ឋបាលរាជធានី ខេត្ត ចំនួន ៣៧% នៃចំណូលប្រមូលបាន
- ប្រាក់រង្វាន់របស់មន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត ចំនួន ៥៨% នៃចំណូលប្រមូលបាន
- ប្រាក់រង្វាន់របស់រដ្ឋបាលរាជធានី ខេត្ត ចំនួន ៣% នៃចំណូលប្រមូលបាន
- ប្រាក់រង្វាន់របស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ចំនួន ១% នៃចំណូលប្រមូលបាន
- ប្រាក់រង្វាន់របស់អគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ ចំនួន ១% នៃចំណូលប្រមូលបាន។

**ប្រការ៣ .–**

ចំណូលពីការពិន័យ ដែលប្រមូលបានដោយក្រសួងពាណិជ្ជកម្ម ត្រូវបែងចែកដូចខាងក្រោម ÷

- បង់ចូលថវិកាជាតិ ចំនួន ៤០% នៃចំណូលប្រមូលបាន
- ប្រាក់រង្វាន់របស់ក្រសួងពាណិជ្ជកម្ម ចំនួន ៥៨% នៃចំណូលប្រមូលបាន
- ប្រាក់រង្វាន់បង់ចូលមូលនិធិ ក.ហ.ស ចំនួន ១% នៃចំណូលប្រមូលបាន
- ប្រាក់រង្វាន់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ១% នៃចំណូលប្រមូលបាន។

**ប្រការ៤ .–**

ចំណូលពីការផ្តន្ទាទោស ដែលក្រសួងពាណិជ្ជកម្មប្រមូលបានដោយអនុវត្តតាមសេចក្តីសម្រេចរបស់សាលាជម្រះក្តី ត្រូវបែងចែកដូចខាងក្រោម ÷

- បង់ចូលថវិកាជាតិ ចំនួន ១៦% នៃចំណូលប្រមូលបាន
- ប្រាក់រង្វាន់របស់ក្រសួងពាណិជ្ជកម្ម ចំនួន ៥៨% នៃចំណូលប្រមូលបាន
- ប្រាក់រង្វាន់សរុបរបស់សាលាជម្រះក្តីពាក់ព័ន្ធ ចំនួន ២៤% នៃចំណូលប្រមូលបាន
- ប្រាក់រង្វាន់បង់ចូលមូលនិធិ ក.ហ.ស ចំនួន ១% នៃចំណូលប្រមូលបាន
- ប្រាក់រង្វាន់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ១% នៃចំណូលប្រមូលបាន។

**ប្រការ៥ .–**

អនុញ្ញាតឱ្យក្រសួងពាណិជ្ជកម្ម បុរេប្រទានប្រាក់រង្វាន់សរុបដែលបានកំណត់ក្នុងប្រការ១ ប្រការ៣ និងប្រការ៤ នៃប្រកាសអន្តរក្រសួងនេះ ដោយដកយកពីចំណូលប្រមូលបាន និងបើកផ្តល់ចំណែកប្រាក់រង្វាន់ជូនដល់អង្គភាពគោលដៅនីមួយៗ។

**ប្រការ៦ .–**

អនុញ្ញាតឱ្យរដ្ឋបាលរាជធានី ខេត្ត បុរេប្រទានប្រាក់រង្វាន់សរុបដែលបានកំណត់ក្នុងប្រការ២ នៃប្រកាសអន្តរក្រសួងនេះ ដោយដកយកពីចំណូលប្រមូលបាន និងបើកផ្តល់ចំណែកប្រាក់រង្វាន់ជូនដល់អង្គភាពគោលដៅនីមួយៗ។

**ប្រការ៧ .-**

ក្រសួងពាណិជ្ជកម្ម និងរដ្ឋបាលរាជធានី ខេត្ត ត្រូវគ្រោងឥណទានចំណាយនៅក្នុងគម្រោងចំណាយថវិកាប្រចាំឆ្នាំរបស់ខ្លួន ដែលជាកម្មវត្ថុសម្រាប់ការធ្វើអាណត្តិនិយ័តកម្មទូទាត់ប្រាក់រង្វាន់ដែលបានបុរេប្រទាន។

ការទូទាត់ប្រាក់រង្វាន់ ត្រូវធ្វើឡើងជារៀងរាល់ខែ ដោយអនុវត្តតាមនីតិវិធីដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ៨ .-**

ការផ្តល់ប្រាក់រង្វាន់ ដែលមានចែងក្នុងប្រកាសអន្តរក្រសួងនេះ ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់សម្រាប់ការចំណាយឧបត្ថម្ភជូនមន្ត្រីរាជការ បុគ្គលិកដែលបំពេញភារកិច្ចផ្ទាល់ និងមន្ត្រី បុគ្គលិកផ្សេងៗទៀត និងប្រើប្រាស់សម្រាប់ការចំណាយពង្រឹងយន្តការប្រមូលចំណូល។

ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃក្រសួងពាណិជ្ជកម្ម ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

ការបើកផ្តល់ប្រាក់រង្វាន់ជូនបុគ្គលិកនៃរដ្ឋបាលរាជធានី ខេត្ត ត្រូវអនុលោមតាមការសម្រេចរបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្តសាមី។

**ប្រការ៩ .-**

ត្រូវបាននិរាករណ៍ប្រកាសអន្តរក្រសួង ដូចខាងក្រោម ÷

១- ប្រកាសអន្តរក្រសួងលេខ១០២៤ សហវ.ប្រក ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្តីពីការផ្តល់រង្វាន់លើកទឹកចិត្តលើការគ្រប់គ្រង និងការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ របស់ក្រសួងពាណិជ្ជកម្ម

២- ប្រកាសអន្តរក្រសួងលេខ៣៣៤ សហវ.ប្រក ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០ ស្តីពីការកែសម្រួលអត្រារង្វាន់លើកទឹកចិត្តលើការគ្រប់គ្រង និងការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ របស់ក្រសួងពាណិជ្ជកម្ម។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១០ .-**

ប្រកាសអន្តរក្រសួងនេះ មានអានុភាពអនុវត្តចាប់ពីថ្ងៃទី..២៦.. ខែ..ឧសភា.. ឆ្នាំ២០២១ តទៅ។

**ប្រការ១១ .-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធ នៃក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងរដ្ឋបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្ត ប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួន។

ថ្ងៃពុធ ៤រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២១

| | |
|---|---|
| **ឧបនាយករដ្ឋមន្ត្រី** | |
| **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** | **រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម** |
| **អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** | **ប៉ាន-សូរស័ក្តិ** |

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួងយុត្តិធម៌
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី២ នៃប្រកាសអន្តរក្រសួងលេខ...៣១៥...... សហវ.ប្រក ចុះថ្ងៃទី...១៨....ខែ...តុលា...ឆ្នាំ២០២១

កម្រងសេវាសាធារណៈ ដែលក្រសួងពាណិជ្ជកម្មធ្វើប្រតិភូកម្មមុខងារជូនរដ្ឋបាលរាជធានី ខេត្ត

| លេខរៀងសេវា | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ១ | ការចេញលិខិតអនុញ្ញាតបិទស្លាកថ្លៃជារូបិយបណ្ណបរទេស | ២០០ ០០០ | ០៥ ថ្ងៃ | ១ ឆ្នាំ |

ព្រះរាជាណាចក្រកម្ពុជា * ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ *

ព្រះរាជាណាចក្រកម្ពុជា * ក្រសួងពាណិជ្ជកម្ម *

ឧបសម្ព័ន្ធទី១ នៃប្រកាសអន្តរក្រសួងលេខ....៣១៥.... សហវ. ប្រក ចុះថ្ងៃទី.១៦..ខែ..តុលា..ឆ្នាំ២០២១

## កម្រងសេវាសាធារណៈ ដែលស្ថិតក្នុងភារកិច្ចរបស់អង្គភាពរដ្ឋបាលកណ្តាលនៃក្រសួងពាណិជ្ជកម្ម

| លេខរៀងសេវា | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| | **I. អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម** | | | |
| | **នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម** | | | |
| | ក. ការសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម | | | |
| ១ | ១ ក្រុមហ៊ុនពាណិជ្ជកម្ម | ១ ០១០ ០០០ | ៣-៧ ថ្ងៃ | ៩៩ ឆ្នាំ |
| ២ | ២ សហគ្រាសឯកបុគ្គល ឬ ពាណិជ្ជករ ដែលត្រូវចុះបញ្ជី | ១៨០ ០០០ | ៣-៧ ថ្ងៃ | ៩៩ ឆ្នាំ |
| | ខ. ការសុំលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម | | | |
| ៣ | ១ ក្រុមហ៊ុនពាណិជ្ជកម្ម | ៤៨០ ០០០ | ៣០ ថ្ងៃ | |
| ៤ | ២ សហគ្រាសឯកបុគ្គល ឬ ពាណិជ្ជករ ដែលបានចុះបញ្ជី | ១៥០ ០០០ | ៣-៧ ថ្ងៃ | |
| | គ. ការសុំចុះបញ្ជីកែប្រែ | | | |
| | ១ ក្រុមហ៊ុនពាណិជ្ជកម្ម | | | |
| ៥ | - ការកែប្រែផ្លាស់ប្តូរភាគហ៊ុន ការបន្ថយដើមទុន ការបង្កើនដើមទុន | ៨០០ ០០០ | ៣-៧ ថ្ងៃ | |
| ៦ | - ការកែប្រែផ្សេងៗ(អភិបាល កម្មវត្ថុអាជីវកម្ម នាមករណ៍ តម្កល់លក្ខន្តិកៈ ទីស្នាក់ការ ។ល។) | ២៤០ ០០០ | ៣-៧ ថ្ងៃ | |
| ៨ | - ការបង្កើតសាខាក្រុមហ៊ុនក្នុងស្រុក | ៤៨០ ០០០ | ៣-៧ ថ្ងៃ | ៩៩ ឆ្នាំ |
| ៩ | ២ សហគ្រាសឯកបុគ្គល ឬ ពាណិជ្ជករ ដែលបានចុះបញ្ជី | ១០០ ០០០ | ៣-៧ ថ្ងៃ | ៩៩ ឆ្នាំ |

| លេខរៀងសេវា | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| | ឃ. ការស្នើសុំលិខិតអនុញ្ញាត ឬអាជ្ញាប័ណ្ណតាមប្រព័ន្ធអេឡិចត្រូនិក | | | |
| ១០ | ១ លិខិតអនុញ្ញាតសម្រាប់រូបវន្តបុគ្គល | ២០០ ០០០ | ៣-៧ ថ្ងៃ | ២ ឆ្នាំ |
| ១១ | ២ លិខិតអនុញ្ញាតសម្រាប់សហគ្រាសឯកបុគ្គល | ៤០០ ០០០ | ៣-៧ ថ្ងៃ | ២ ឆ្នាំ |
| ១២ | ៣ អាជ្ញាប័ណ្ណ | ១ ០០០ ០០០ | ៥-១០ ថ្ងៃ | ៣ ឆ្នាំ |
| | ង. ការបន្តសុពលភាពលិខិតអនុញ្ញាត ឬអាជ្ញាប័ណ្ណតាមប្រព័ន្ធអេឡិចត្រូនិក | | | |
| ១៣ | ១ លិខិតអនុញ្ញាតសម្រាប់រូបវន្តបុគ្គល | ២០០ ០០០ | ១-៣ ថ្ងៃ | ២ ឆ្នាំ |
| ១៤ | ២ លិខិតអនុញ្ញាតសម្រាប់សហគ្រាសឯកបុគ្គល | ៤០០ ០០០ | ១-៣ ថ្ងៃ | ២ ឆ្នាំ |
| ១៥ | ៣ អាជ្ញាប័ណ្ណ | ១ ០០០ ០០០ | ៣-៧ ថ្ងៃ | ៣ ឆ្នាំ |
| | ច. ការកែប្រែលិខិតអនុញ្ញាត ឬអាជ្ញាប័ណ្ណ | | | |
| | ១ ការកែប្រែលិខិតអនុញ្ញាត | | | |
| ១៦ | - កែប្រែឈ្មោះអាជីវកម្ម សហគ្រាស | ១០០ ០០០ | ៣-៥ ថ្ងៃ | |
| ១៧ | - កែប្រែកម្មវត្ថុអាជីវកម្ម ឬគំរូអាជីវកម្ម | ១០០ ០០០ | ៣-៥ ថ្ងៃ | |
| ១៨ | - កែប្រែវិញ្ញាបនបត្រសេវាអនឡាញ និងឈ្មោះដែន | ១០០ ០០០ | ៣-៥ ថ្ងៃ | |
| ១៩ | - កែប្រែមធ្យោបាយអេឡិចត្រូនិកសម្រាប់ទំនាក់ទំនង | ១០០ ០០០ | ៣-៥ ថ្ងៃ | |
| | ២ ការកែប្រែអាជ្ញាប័ណ្ណ | | | |
| ២០ | - កែប្រែឈ្មោះក្រុមហ៊ុន | ២៤០ ០០០ | ៣-៧ ថ្ងៃ | |
| ២១ | - កែប្រែកម្មវត្ថុអាជីវកម្ម ឬគំរូអាជីវកម្ម | ២៤០ ០០០ | ៣-៧ ថ្ងៃ | |

| លេខរៀងសេវា | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ២២ | - កែប្រែវិញ្ញាបនបត្រសេវាអនឡាញ និងឈ្មោះដែន | ២៤០ ០០០ | ៣-៧ ថ្ងៃ | |
| ២៣ | - កែប្រែមធ្យោបាយអេឡិចត្រូនិកសម្រាប់ទំនាក់ទំនង | ២៤០ ០០០ | ៣-៧ ថ្ងៃ | |
| ២៤ | - កែប្រែគំរូកិច្ចសន្យារវាងអន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្ម | ២៤០ ០០០ | ៣-៧ ថ្ងៃ | |
| | ឆ. ការផ្អាក ឬបិទអាជីវកម្ម | | | |
| ២៥ | ១ លិខិតអនុញ្ញាតសម្រាប់រូបវន្តបុគ្គល | ១០០ ០០០ | ៣-៥ ថ្ងៃ | |
| ២៦ | ២ លិខិតអនុញ្ញាតសម្រាប់សហគ្រាសឯកបុគ្គល | ២០០ ០០០ | ៣-៥ ថ្ងៃ | |
| ២៧ | ៣ អាជ្ញាប័ណ្ណ | ៥០០ ០០០ | ៣-៥ ថ្ងៃ | |
| ២៨ | ជ. ការតម្កល់ប្រតិវេទីប្រចាំឆ្នាំ | ៨០ ០០០ | ១ ថ្ងៃ | ១ ឆ្នាំ |
| ២៩ | ឈ. ការថតចម្លងឯកសារចុះបញ្ជីពាណិជ្ជកម្ម | ៨០ ០០០ | ៣ ថ្ងៃ | |
| ៣០ | ញ. ទទួលពាក្យស្នើសុំអនុវត្តដីការរក្សាការពារ និងទទួលពាក្យសម្របសម្រួលដោះស្រាយវិវាទ | ១ ០០០ ០០០ | ១ ថ្ងៃ | |
| ៣១ | ដ. ការពិនិត្យនាមករណ៍ក្រុមហ៊ុន សហគ្រាស | ២៥ ០០០ | ១-៣ ថ្ងៃ | ១៥ ថ្ងៃ |
| ៣២ | ឋ. លិខិតបញ្ជាក់ផ្សេងៗ ផ្ទេរសិទ្ធិអ្នកប្រើប្រាស់ប្រព័ន្ធ (តាមការស្នើសុំ) | ១៦០ ០០០ | ៣-៥ ថ្ងៃ | ១ ដង |
| ៣៣ | ឌ. ការទាញយកវិញ្ញាបនបត្រ ឬ ការទាញយកសម្រង់ព័ត៌មាន ជាថ្មីទៀតពីប្រព័ន្ធស្វ័យប្រវត្តិកម្ម | ៨០ ០០០ | | ១ ដង |
| | ឍ. ការងារពិគ្រោះយោបល់ផ្នែកច្បាប់ (តាមការស្នើសុំ) | | | |
| ៣៤ | ១ សេវាពិគ្រោះយោបល់ចុះបញ្ជីពាណិជ្ជកម្ម ៖ | ៤០០ ០០០ | ១ ថ្ងៃ | |
| | - ពិនិត្យ និងបញ្ជាក់លើភាពត្រឹមត្រូវនៃឯកសារតម្រូវសម្រាប់ការស្នើសុំចុះបញ្ជីពាណិជ្ជកម្ម | | | |

| លេខរៀងសេវា | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| | - បញ្ជាក់ពីអនុលោមភាពនៃច្បាប់លើការរៀបចំខ្លឹមសារនៃកិច្ចសន្យា ឬ លក្ខន្តិកៈបង្កើតក្រុមហ៊ុន | | | |
| | - ពិនិត្យ និងបញ្ជាក់លើសុពលភាពនៃសិទ្ធិប្រាតិភោគលើភាគហ៊ុនរបស់ក្រុមហ៊ុន | | | |
| | - ជួយផ្តល់សេវាពិនិត្យផ្ទៀងផ្ទាត់ការបកប្រែភាសាលើឯកសារចុះបញ្ជីពាណិជ្ជកម្ម និងឯកសារកែប្រែលក្ខន្តិកៈក្រុមហ៊ុនដែលមានការចាំបាច់ | | | |
| ៣៥ | ២ សេវាពិគ្រោះយោបល់ផ្នែកច្បាប់ទាក់ទងនឹងការកែប្រែលក្ខន្តិកៈក្រុមហ៊ុន ÷ | ២០០ ០០០ | ១ ថ្ងៃ | |
| | - បញ្ជាក់ពីអនុលោមភាពនៃច្បាប់លើការរៀបចំខ្លឹមសារនៃកិច្ចសន្យាឬលក្ខន្តិកៈបង្កើតក្រុមហ៊ុន | | | |
| | - ពិនិត្យនិងបញ្ជាក់លើសុពលភាពនៃសិទ្ធិប្រាតិភោគលើភាគហ៊ុនរបស់ក្រុមហ៊ុន | | | |
| | - ជួយផ្តល់សេវាពិនិត្យផ្ទៀងផ្ទាត់ការបកប្រែភាសាលើឯកសារចុះបញ្ជីពាណិជ្ជកម្ម និងឯកសារកែប្រែលក្ខន្តិកៈក្រុមហ៊ុនដែលមានការចាំបាច់ | | | |
| ៣៦ | ៣ សេវារៀបចំលក្ខន្តិកៈក្រុមហ៊ុន (ចុះបញ្ជីពាណិជ្ជកម្មថ្មី និងការកែប្រែលក្ខន្តិកៈ) | ៤០០ ០០០ | ២ ថ្ងៃ | |
| | **នាយកដ្ឋានកម្មសិទ្ធិបញ្ញា** | | | |
| ៣៧ | ១ ការដាក់ពាក្យស្នើសុំចុះបញ្ជី ការត្រួតពិនិត្យលម្អិត ការចុះបញ្ជី និងបោះពុម្ពផ្សាយម៉ាក ក្នុងមួយជំពូក | ៤២០ ០០០ | ៥-៧ ខែ | ១០ ឆ្នាំ |
| ៣៨ | ២ ការដាក់ពាក្យស្នើសុំ ការត្រួតពិនិត្យលម្អិត ការចុះបញ្ជី និងការបោះពុម្ពផ្សាយម៉ាកសមូហភាព ឬម៉ាកវិញ្ញាតកម្ម ក្នុងមួយជំពូក | ៤២០ ០០០ | ៥-៧ ខែ | ១០ ឆ្នាំ |
| ៣៩ | ៣ ការដាក់ពាក្យស្នើសុំ ការត្រួតពិនិត្យលម្អិត ការចុះបញ្ជី និងការបោះពុម្ពផ្សាយម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ | ៤២០ ០០០ | ៦-១២ ខែ | គ្មានកាលកំណត់ |
| ៤០ | ៤ ការដាក់ពាក្យស្នើសុំបញ្ជាក់អំពីការប្រើប្រាស់ ឬមិនបានប្រើប្រាស់ ម៉ាក ម៉ាកសមូហភាព ម៉ាកវិញ្ញាតកម្ម ឬ ម៉ាកក្នុងក្របខណ្ឌអន្តរជាតិ | ១០០ ០០០ | ៦០ ថ្ងៃ | ៥ ឆ្នាំ |

| លេខរៀងសេវា | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ៤១ | ៥ ការផ្លាស់ប្តូរផ្សេងៗ | ១០០ ០០០ | ៦០ ថ្ងៃ | គ្មានកាលកំណត់ |
| ៤២ | ៦ ការស្នើសុំពន្យារពេលដើម្បីផ្តល់ភស្តុតាង ឬឯកសារគាំទ្រផ្សេងៗបន្ថែម | ៤០ ០០០ | ១០ ថ្ងៃ | |
| ៤៣ | ៧ ការដាក់ពាក្យស្នើសុំ និងពិនិត្យបណ្តឹង ជំទាស់ ធ្វើមោឃភាព ឬលុបការចុះបញ្ជីម៉ាក ម៉ាកសមូហភាព ម៉ាកវិញ្ញាតកម្ម ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ការកត់ត្រាសិទ្ធិផ្តាច់មុខ ឬកិច្ចសន្យាអាជ្ញាប័ណ្ណ/កិច្ចសន្យាផ្តល់សិទ្ធិប្រកបអាជីវកម្ម ចេញពីបញ្ជី | ៣០០ ០០០ | ៦០ ថ្ងៃ | |
| ៤៤ | ៨ ការលុបម៉ាក ម៉ាកសមូហភាព ម៉ាកវិញ្ញាតកម្ម ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ការកត់ត្រាសិទ្ធិផ្តាច់មុខ ឬកិច្ចសន្យាអាជ្ញាប័ណ្ណ/កិច្ចសន្យាផ្តល់សិទ្ធិប្រកបអាជីវកម្ម ចេញពីបញ្ជី និងការបោះពុម្ពផ្សាយ | ៣០០ ០០០ | តាមករណី | |
| ៤៥ | ៩ ការដាក់ពាក្យ ការចុះបញ្ជីសាជាថ្មី និងបោះពុម្ពផ្សាយម៉ាក ម៉ាកសមូហភាព ឬម៉ាកវិញ្ញាតកម្ម | ៤២០ ០០០ | ៦០ ថ្ងៃ | ១០ ឆ្នាំ |
| ៤៦ | ១០ ការស្នើសុំកត់ត្រា និងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខ | ៦០០ ០០០ | ៦០ ថ្ងៃ | មិនលើស ២ ឆ្នាំ |
| ៤៧ | ១១ ការស្នើសុំកត់ត្រាកិច្ចសន្យាអាជ្ញាប័ណ្ណ/កិច្ចសន្យាផ្តល់សិទ្ធិប្រកបអាជីវកម្ម | ៤០០ ០០០ | ៦០ ថ្ងៃ | តាមកិច្ចសន្យា |
| ៤៨ | ១២ ការស្នើសុំលុបម៉ាក ម៉ាកសមូហភាព ម៉ាកវិញ្ញាតកម្ម ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ការកត់ត្រាសិទ្ធិផ្តាច់មុខ ឬការកត់ត្រាកិច្ចសន្យាអាជ្ញាប័ណ្ណ/កិច្ចសន្យាផ្តល់សិទ្ធិប្រកបអាជីវកម្ម ដោយម្ចាស់ម៉ាក ឬភ្នាក់ងារតំណាង | ១២០ ០០០ | ៦០ ថ្ងៃ | |
| ៤៩ | ១៣ ការស្នើសុំពិនិត្យ និងវាយតម្លៃម៉ាក មុនការដាក់ពាក្យស្នើសុំចុះបញ្ជី | ៨០ ០០០ | ៦០ ថ្ងៃ | |
| ៥០ | ១៤ ការស្នើសុំទុតិយតាវិញ្ញាបនបត្រ ចម្លងត្រឹមត្រូវតាមច្បាប់ដើម ថតចម្លងឯកសារ ការបញ្ជាក់សុពលភាពម៉ាក ឬការបញ្ជាក់ផ្សេងៗ | ១០០ ០០០ | ៦០ ថ្ងៃ | |
| ៥១ | ១៥ ការដាក់ពាក្យស្នើសុំសម្រុះសម្រួលវិវាទ | ២០០ ០០០ | ៣០ ថ្ងៃ | |
| ៥២ | ១៦ ការវាយតម្លៃអំពីការរំលោភបំពាន | ២០០ ០០០ | ៦០ ថ្ងៃ | |

| លេខរៀងសេវា | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ៥៣ | ១៧ ការបញ្ជាក់ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ក្នុងមួយជំពូក | ១០០ ០០០ | ៦០ ថ្ងៃ | |
| ៥៤ | ១៨ ការស្នើសុំចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ដែលកម្ពុជាត្រូវបានជ្រើសរើស ក្នុងមួយជំពូក និងបោះពុម្ពផ្សាយ | ៦០០ ០០០ | តាមបទប្បញ្ញត្តិនៃការចុះបញ្ជីម៉ាកក្នុងក្របខ័ណ្ឌអន្តរជាតិ | ១០ ឆ្នាំ |
| ៥៥ | ១៩ ការស្នើសុំចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិសាជាថ្មី ក្នុងមួយជំពូក | ៦០០ ០០០ | តាមបទប្បញ្ញត្តិនៃការចុះបញ្ជីម៉ាកក្នុងក្របខ័ណ្ឌអន្តរជាតិ | ១០ ឆ្នាំ |
| ៥៦ | ២០ ការសុំប្តូរម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ទៅជាម៉ាកថ្នាក់ជាតិ និងបោះពុម្ពផ្សាយ | ៤២០ ០០០ | តាមបទប្បញ្ញត្តិនៃការចុះបញ្ជីម៉ាកក្នុងក្របខ័ណ្ឌអន្តរជាតិ | ១០ ឆ្នាំ |
| ៥៧ | ២១ ការជំនួសម៉ាកជាតិទៅជាម៉ាកក្នុងក្របខណ្ឌអន្តរជាតិ និងបោះពុម្ពផ្សាយ | ១០០ ០០០ | តាមបទប្បញ្ញត្តិនៃការចុះបញ្ជីម៉ាកក្នុងក្របខ័ណ្ឌអន្តរជាតិ | ១០ ឆ្នាំ |
| ៥៨ | ២២ ការស្នើសុំទទួលស្គាល់ជាភ្នាក់ងារតំណាងម្ចាស់ម៉ាក | ១០០ ០០០ | | ១ ឆ្នាំ |
| | **នាយកដ្ឋាននាំចេញ-នាំចូល និងតំណាងពាណិជ្ជកម្មតំបន់សេដ្ឋកិច្ចពិសេស** | | | |
| | ក. សេវាចេញវិញ្ញាបនបត្រប្រភពដើមទំនិញ | | | |
| | ១ សម្លៀកបំពាក់ | | | |

| លេខរៀងសេវា | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| | - ទម្រង់ A: | | | |
| ៥៩ | ច្រើនជាង ឬ ស្មើ ២ ០០០PCS | ២១៦ ០០០ | ១៦ ម៉ោង | ៦-១២ ខែ |
| ៦០ | តិចជាង ២ ០០០PCS | ៨៦ ០០០ | ១៦ ម៉ោង | ៦-១២ ខែ |
| | - ទម្រង់ N: | | | |
| ៦១ | ច្រើនជាង ឬ ស្មើ ២ ០០០PCS | ១៤២ ០០០ | ១៦ ម៉ោង | ៦-១២ ខែ |
| ៦២ | តិចជាង ២ ០០០PCS | ៦៧ ០០០ | ១៦ ម៉ោង | ៦-១២ ខែ |
| | - ទម្រង់ផ្សេងទៀត | | | |
| ៦៣ | ច្រើនជាង ឬ ស្មើ ២ ០០០PCS | ២១៦ ០០០ | ១៦ ម៉ោង | ៦-១២ ខែ |
| ៦៤ | តិចជាង ២ ០០០PCS | ៨៦ ០០០ | ១៦ ម៉ោង | ៦-១២ ខែ |
| | ២ ក្រណាត់ | | | |
| ៦៥ | - ទម្រង់ A | ២១៦ ០០០ | ១៦ ម៉ោង | ៦-១២ ខែ |
| ៦៦ | - ទម្រង់ N | ១៤២ ០០០ | ១៦ ម៉ោង | ៦-១២ ខែ |
| ៦៧ | - ទម្រង់ផ្សេងទៀត | ២១៦ ០០០ | ១៦ ម៉ោង | ៦-១២ ខែ |
| | ៣ ស្បែកជើង | | | |
| | - ទម្រង់ A | | | |
| ៦៨ | ច្រើនជាង ឬ ស្មើ ២០០PRS | ២១៦ ០០០ | ១៦ ម៉ោង | ៦-១២ ខែ |
| ៦៩ | តិចជាង ២០០PRS | ៨៦ ០០០ | ១៦ ម៉ោង | ៦-១២ ខែ |

| លេខរៀងសេវា | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្ដល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| | - ទម្រង់ N | | | |
| ៧០ | ច្រើនជាង ឬ ស្មើ ២០០PRS | ១៤២ ០០០ | ១៦ ម៉ោង | ៦-១២ ខែ |
| ៧១ | តិចជាង ២០០PRS | ៦៧ ០០០ | ១៦ ម៉ោង | ៦-១២ ខែ |
| | - ទម្រង់ផ្សេងទៀត | | | |
| ៧២ | ច្រើនជាង ឬ ស្មើ ២០០PRS | ២១៦ ០០០ | ១៦ ម៉ោង | ៦-១២ ខែ |
| ៧៣ | តិចជាង ២០០PRS | ៨៦ ០០០ | ១៦ ម៉ោង | ៦-១២ ខែ |
| ៧៤ | ៤ អង្ករ (គ្រប់ទម្រង់) | មិនគិតថ្លៃ | ១៦ ម៉ោង | ៦-១២ ខែ |
| ៧៥ | ៥ ទំនិញសិប្បកម្មតូច (គ្រប់ទម្រង់) | មិនគិតថ្លៃ | ១៦ ម៉ោង | ៦-១២ ខែ |
| ៧៦ | ៦ ទំនិញកសិផល÷ ដំឡូង ពោត សណ្ដែក ម្ទេស ល្ង ស្វាយ បន្លែ និងផ្លែឈើផ្សេងៗទៀត (គ្រប់ទម្រង់) | មិនគិតថ្លៃ | ១៦ ម៉ោង | ៦-១២ ខែ |
| | ៧ ទំនិញទូទៅ | | | |
| ៧៧ | - ទម្រង់ A | ២១៦ ០០០ | ១៦ ម៉ោង | ៦-១២ ខែ |
| ៧៨ | - ទម្រង់ N | ១៤២ ០០០ | ១៦ ម៉ោង | ៦-១២ ខែ |
| ៧៩ | - ទម្រង់ផ្សេងទៀត | ២១៦ ០០០ | ១៦ ម៉ោង | ៦-១២ ខែ |
| | ៨ ការកែតម្រូវ ឬ ចេញច្បាប់ទុតិយតានៃវិញ្ញាបនបត្រប្រភពដើមទំនិញ | | | |
| | - ទម្រង់ A | | | |
| ៨០ | ច្រើនជាង ឬ ស្មើ ២ ០០០PCS/PRS | ២១៦ ០០០ | ១៦ ម៉ោង | ៦-១២ ខែ |
| ៨១ | តិចជាង ២ ០០០PCS/PRS | ៨៦ ០០០ | ១៦ ម៉ោង | ៦-១២ ខែ |

| លេខរៀងសេវា | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| | - ទម្រង់ N | | | |
| ៨២ | ច្រើនជាង ឬ ស្មើ ២ ០០០PCS/PRS | ១៤២ ០០០ | ១៦ ម៉ោង | ៦-១២ ខែ |
| ៨៣ | តិចជាង ២ ០០០PCS/PRS | ៦៧ ០០០ | ១៦ ម៉ោង | ៦-១២ ខែ |
| | - ទម្រង់ផ្សេងទៀត | | | |
| ៨៤ | ច្រើនជាង ឬ ស្មើ ២ ០០០PCS/PRS | ២១៦ ០០០ | ១៦ ម៉ោង | ៦-១២ ខែ |
| ៨៥ | តិចជាង ២ ០០០PCS/PRS | ៨៦ ០០០ | ១៦ ម៉ោង | ៦-១២ ខែ |
| | ខ. អាជ្ញាប័ណ្ណនាំចេញ ឬ ការពន្យាសុពលភាពអាជ្ញាប័ណ្ណនាំចេញ | | | |
| ៨៦ | - ផលិតផលឈើកែច្នៃ | ៨០០ ០០០ | ១៦ ម៉ោង | ២ ខែ ឬ ៤៥ ថ្ងៃ |
| ៨៧ | - ក្រៅពីផលិតផលឈើកែច្នៃ | ៤០០ ០០០ | ១៦ ម៉ោង | ២ ខែ ឬ ៤៥ ថ្ងៃ |
| | គ. អាជ្ញាប័ណ្ណនាំចូល ឬ ការពន្យាសុពលភាពអាជ្ញាប័ណ្ណនាំចូល | | | |
| ៨៨ | - ផលិតផលឈើកែច្នៃ | ៨០០ ០០០ | ១៦ ម៉ោង | ៣ ខែ ឬ ៤៥ ថ្ងៃ |
| ៨៩ | - ក្រៅពីផលិតផលឈើកែច្នៃ | ៤០០ ០០០ | ១៦ ម៉ោង | ៣ ខែ ឬ ៤៥ ថ្ងៃ |
| ៩០ | ឃ. សេវាចេញវិញ្ញាបនបត្រនាំចូលត្បូងថ្មមិនទាន់ច្នៃក្រោម Kimberly Proccess | ២០០ ០០០ | ១៦ ម៉ោង | |
| ៩១ | ង. សេវាចេញវិញ្ញាបនបត្រនាំចេញត្បូងថ្មមិនទាន់ច្នៃក្រោម Kimberly Proccess | ១០០ ០០០ | ១៦ ម៉ោង | |
| | ច. សេវាចុះបញ្ជិការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្មក្នុងការចេញវិញ្ញាបនបត្រប្រភពដើមទំនិញ ឬ សម្រាប់ស្វ័យបញ្ជាក់ប្រភពដើមទំនិញ | | | |
| ៩២ | - ការចុះបញ្ជីលើកដំបូង | ៤០០ ០០០ | ៣-៥ ថ្ងៃ | អចិន្ត្រៃយ៍ |
| ៩៣ | - កែសម្រួលឡើងវិញ ឬ ចុះបញ្ជីសារជាថ្មី | ២០០ ០០០ | ៣-៥ ថ្ងៃ | |
| ៩៤ | ឆ. ចេញលិខិតជូនដំណឹងដឹកជញ្ជូនទំនិញឆ្លងកាត់ក្នុង ១ច្បាប់ | ៤០០ ០០០ | ៣-៥ ថ្ងៃ | |

| លេខរៀងសេវា | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| | II. **អគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស** | | | |
| | **នាយកដ្ឋានអភិវឌ្ឍន៍វិស័យឯកជន** | | | |
| ៩៥ | ១ កម្រៃទទួលតម្កល់លក្ខន្តិកៈសមាគមអាជីវកម្មនៅកម្ពុជា | មិនគិតថ្លៃ | ១៥ ថ្ងៃ | |
| | **នាយកដ្ឋាននីតិកម្ម** | | | |
| ៩៦ | ១ តម្កល់លិខិតជូនដំណឹងដំបូង លើសិទ្ធិប្រាតិភោគ | ៤០ ០០០ | ស្វ័យប្រវត្តិកម្ម | ៥ ឆ្នាំ |
| ៩៧ | ២ តម្កល់វិសោធនកម្មលើលិខិតជូនដំណឹង (មួយដង) | ៤០ ០០០ | ស្វ័យប្រវត្តិកម្ម | ៥ ឆ្នាំ |
| ៩៨ | ៣ តម្កល់លិខិតសុំបន្ត | ៤០ ០០០ | ស្វ័យប្រវត្តិកម្ម | ៥ ឆ្នាំ |
| ៩៩ | ៤ តម្កល់លិខិតសុំកែតម្រូវ (មួយដង) | ៤០ ០០០ | ស្វ័យប្រវត្តិកម្ម | ៥ ឆ្នាំ |
| ១០០ | ៥ តម្កល់លិខិតសុំបញ្ចប់ (មួយដង) | ៤០ ០០០ | ស្វ័យប្រវត្តិកម្ម | - |
| ១០១ | ៦ សេវារៀបចំរបាយការណ៍ស្រាវជ្រាវដែលមានការបញ្ជាក់ (មួយដង) | ៤០ ០០០ | ៥ ថ្ងៃ | - |
| | III. **អគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម** | | | |
| | **នាយកដ្ឋានកិច្ចការពិព័រណ៍** | | | |
| ១០២ | ១ ការចេញលិខិតអនុញ្ញាតរៀបចំពិព័រណ៍ | ១ ៤០០ ០០០ | ៧ ថ្ងៃ | |
| | ២ កម្រៃនៃការគ្រប់គ្រង និងចាត់ចែងពិព័រណ៍(គិតក្នុង ១ស្តង់) | | | |
| ១០៣ | - វិស័យទូទៅ( ប្រធានបទពាក់ព័ន្ធនឹងវិជ្ជាជីវៈ) | ១០០ ០០០ | ៧ ថ្ងៃ | |
| ១០៤ | - ពិព័រណ៍ដែលមានប្រធានបទបម្រើវិស័យកសិកម្ម ជាលក្ខណៈអន្តរជាតិ | ២០ ០០០ | ៧ ថ្ងៃ | |
| | IV. **អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ** | | | |
| | **នាយកដ្ឋានមន្ទីរពិសោធន៍** | | | |

| លេខរៀងសេវា | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្ដល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| | ក. ការវិភាគលើគំរូផលិតផលនៅមន្ទីរពិសោធន៍ | | | |
| | ១ ការវិភាគគីមីសម្រាប់ម្ហូបអាហារ | | | |
| | ១.១ ប៉ារ៉ាម៉ែត្រគុណភាពសម្រាប់ម្ហូបអាហារទូទៅ (Quality Parameters for General Food) | | | |
| ១០៥ | - Acid Value | ៤០ ០០០ | ៣-១០ ថ្ងៃ | |
| ១០៦ | - Alkalinity | ៤០ ០០០ | ៣-១០ ថ្ងៃ | |
| ១០៧ | - Ash Content | ៨០ ០០០ | ៣-១០ ថ្ងៃ | |
| ១០៨ | - pH-Value | ២០ ០០០ | ៣-១០ ថ្ងៃ | |
| ១០៩ | - Crude Fat | ១២០ ០០០ | ៣-១០ ថ្ងៃ | |
| ១១០ | - Density | ៤០ ០០០ | ៣-១០ ថ្ងៃ | |
| ១១១ | - Dietary Fiber | ២០០ ០០០ | ៣-១០ ថ្ងៃ | |
| ១១២ | - Foreign Matters | ២០ ០០០ | ៣-១០ ថ្ងៃ | |
| ១១៣ | - Impurities | ៤០ ០០០ | ៣-១០ ថ្ងៃ | |
| ១១៤ | - Moisture by Air Oven | ១០០ ០០០ | ៣-១០ ថ្ងៃ | |
| ១១៥ | - Moisture by Karlfischer | ២០០ ០០០ | ៣-១០ ថ្ងៃ | |
| ១១៦ | - Moisture by Moisture Balance | ៥០ ០០០ | ៣-១០ ថ្ងៃ | |
| ១១៧ | - Moisture by Moisture Meter | ៣០ ០០០ | ៣-១០ ថ្ងៃ | |
| ១១៨ | - Water content by distillation | ៨០ ០០០ | ៣-១០ ថ្ងៃ | |

| លេខរៀងសេវា | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ១១៩ | - Protein by Kjedahl | ១៥០ ០០០ | ៣-១០ ថ្ងៃ | |
| ១២០ | - Starch | ១២០ ០០០ | ៣-១០ ថ្ងៃ | |
| ១២១ | - Total Nitrogen | ១៥០ ០០០ | ៣-១០ ថ្ងៃ | |
| ១២២ | - Total solids | ៥០ ០០០ | ៣-១០ ថ្ងៃ | |
| ១២៣ | - Total Volatile Bases -Nitrogen (TVB-N) in Fish | ១២០ ០០០ | ៣-១០ ថ្ងៃ | |
| | ១.២ ប៉ារ៉ាម៉ែត្រគុណភាពសម្រាប់ខ្លាញ់ និងប្រេង (Quality Parameters for Fats and Oils) | | | |
| ១២៤ | - Acid Value, free fatty acids (FFA) | ៦០ ០០០ | ៣-១០ ថ្ងៃ | |
| ១២៥ | - Iodine Value | ៦០ ០០០ | ៣-១០ ថ្ងៃ | |
| ១២៦ | - Peroxide Value | ៦០ ០០០ | ៣-១០ ថ្ងៃ | |
| ១២៧ | - Saponification Value | ៦០ ០០០ | ៣-១០ ថ្ងៃ | |
| ១២៨ | - Unsaponification Value | ៦០ ០០០ | ៣-១០ ថ្ងៃ | |
| | ១.៣ ប៉ារ៉ាម៉ែត្រសម្រាប់ភេសជ្ជៈអាល់កុល (Parameters for Alcoholic Beverages) | | | |
| ១២៩ | - Acidity | ៥០ ០០០ | ៣-១០ ថ្ងៃ | |
| ១៣០ | - Alcoholic Degree (Hydrometer) | ៥០ ០០០ | ៣-១០ ថ្ងៃ | |
| ១៣១ | - Ethanol by Refractometer | ៤០ ០០០ | ៣-១០ ថ្ងៃ | |
| ១៣២ | - Methanol by Chromotropic Acid | ៨០ ០០០ | ៣-១០ ថ្ងៃ | |
| ១៣៣ | - Esters by Titration | ៥០ ០០០ | ៣-១០ ថ្ងៃ | |
| ១៣៤ | - Aldehydes by Titration | ៦០ ០០០ | ៣-១០ ថ្ងៃ | |

| លេខរៀងសេវា | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ១៣៥ | - Higher Alcohols (Fufural) | ៨០ ០០០ | ៣-១០ ថ្ងៃ | |
| ១៣៦ | - Sulfur Dioxide in Wine | ៨០ ០០០ | ៣-១០ ថ្ងៃ | |
| | ១.៤ ស្ករ និងទឹកឃ្មុំ (Sugars and Honey) | | | |
| ១៣៧ | - Sucrose by Polarimeter | ៩០ ០០០ | ៣-១០ ថ្ងៃ | |
| ១៣៨ | - Invert Sugar by Titration | ៨០ ០០០ | ៣-១០ ថ្ងៃ | |
| ១៣៩ | - Reducing Sugar by Titration | ៨០ ០០០ | ៣-១០ ថ្ងៃ | |
| ១៤០ | - Hydroxymethylfufural (HMF) in Honey | ១០០ ០០០ | ៣-១០ ថ្ងៃ | |
| | ១.៥ សារធាតុបន្ថែមក្នុងម្ហូបអាហារ (Food Additives) | | | |
| ១៤១ | - Cafein by HPLC | ៩០ ០០០ | ៣-១០ ថ្ងៃ | |
| ១៤២ | - Benzoic Acid / Sorbic Acid by HPLC | ៩០ ០០០ | ៣-១០ ថ្ងៃ | |
| ១៤៣ | - Nitrate | ៧០ ០០០ | ៣-១០ ថ្ងៃ | |
| ១៤៤ | - Nitrite | ៧០ ០០០ | ៣-១០ ថ្ងៃ | |
| ១៤៥ | - Sulfites in Food by Titration | ៨០ ០០០ | ៣-១០ ថ្ងៃ | |
| ១៤៦ | - Monosodium L-Glutamate | ៩០ ០០០ | ៣-១០ ថ្ងៃ | |
| ១៤៧ | - Food Color by HPLC | ១០០ ០០០ | ៣-១០ ថ្ងៃ | |
| ១៤៨ | - Sweeteners in Food by HPLC | ១០០ ០០០ | ៣-១០ថ្ងៃ | |
| | ១.៦ សារធាតុគីមីហាមឃាត់ដាក់បញ្ចូលក្នុងម្ហូបអាហារ (Chemical Adulterants) | | | |
| ១៤៩ | - Borax / Boric Acid (Qualitative) | ៣០ ០០០ | ៣-១០ ថ្ងៃ | |

| លេខរៀងសេវា | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ១៥០ | - Borax / Boric Acid (Semiquantitative) | ៥០ 000 | ៣-១០ ថ្ងៃ | |
| ១៥១ | - Formaldehyde (Qualitative) | ៤០ 000 | ៣-១០ ថ្ងៃ | |
| ១៥២ | - Free Mineral Acid in Vinegar | ៥០ 000 | ៣-១០ ថ្ងៃ | |
| ១៥៣ | - Malamine in Milk and diary products by GC-MS | ១៣០ 000 | ៣-១០ ថ្ងៃ | |
| ១៥៤ | - Para Red by HPLC | ១០០ 000 | ៣-១០ ថ្ងៃ | |
| ១៥៥ | - Rodamine B by HPLC | ១០០ 000 | ៣-១០ ថ្ងៃ | |
| ១៥៦ | - Salicylic Acid (Qualitative) | ៤០ 000 | ៣-១០ ថ្ងៃ | |
| ១៥៧ | - Sodium Hydrosulfite (Qualitative) | ៤០ 000 | ៣-១០ ថ្ងៃ | |
| ១៥៨ | - Sudan red I,II,III,IV by HPLC | ១០០ 000 | ៣-១០ ថ្ងៃ | |
| | ១.៧ សារធាតុខនិក និងសារធាតុចម្លង (Minerals and Contaminants) | | | |
| ១៥៩ | - Antimony | ៩០ 000 | ៣-១០ ថ្ងៃ | |
| ១៦០ | - Arsenic | ៩០ 000 | ៣-១០ ថ្ងៃ | |
| ១៦១ | - Cadmium | ៩០ 000 | ៣-១០ ថ្ងៃ | |
| ១៦២ | - Calcium | ៩០ 000 | ៣-១០ ថ្ងៃ | |
| ១៦៣ | - Copper | ៩០ 000 | ៣-១០ ថ្ងៃ | |
| ១៦៤ | - Iron | ៩០ 000 | ៣-១០ ថ្ងៃ | |
| ១៦៥ | - Lead | ៩០ 000 | ៣-១០ ថ្ងៃ | |

| លេខរៀងសេវា | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ១៦៦ | - Manganese | ៩០ ០០០ | ៣-១០ ថ្ងៃ | |
| ១៦៧ | - Mercury | ៩០ ០០០ | ៣-១០ ថ្ងៃ | |
| ១៦៨ | - Potassium | ៩០ ០០០ | ៣-១០ ថ្ងៃ | |
| ១៦៩ | - Zinc | ៩០ ០០០ | ៣-១០ ថ្ងៃ | |
| ១៧០ | - Selenium | ៩០ ០០០ | ៣-១០ ថ្ងៃ | |
| ១៧១ | - Sodium | ៩០ ០០០ | ៣-១០ ថ្ងៃ | |
| | ១.៨ ការវិភាគជាតិអាហាររូបត្ថម្ភ និងព័ត៌មានអះអាងលើស្លាកសញ្ញា (Test for Nutrition Facts and Labeling Claims) | | | |
| ១៧២ | - Cholesterol | ៨០ ០០០ | ៣-១០ ថ្ងៃ | |
| ១៧៣ | - Dietary Fiber | ១២០ ០០០ | ៣-១០ ថ្ងៃ | |
| ១៧៤ | - Drained Weight | ៨០ ០០០ | ៣-១០ ថ្ងៃ | |
| ១៧៥ | - Iodine Value | ៨០ ០០០ | ៣-១០ ថ្ងៃ | |
| ១៧៦ | - Protein | ១២០ ០០០ | ៣-១០ ថ្ងៃ | |
| ១៧៧ | - Sodium | ១២០ ០០០ | ៣-១០ ថ្ងៃ | |
| ១៧៨ | - Total Carbohydrates | ១២០ ០០០ | ៣-១០ ថ្ងៃ | |
| ១៧៩ | - Starch | ៩០ ០០០ | ៣-១០ ថ្ងៃ | |
| ១៨០ | - Total Fat | ៩០ ០០០ | ៣-១០ ថ្ងៃ | |
| ១៨១ | - Vitamin C | ១០០ ០០០ | ៣-១០ ថ្ងៃ | |

| លេខរៀងសេវា | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ១៨២ | - Energy Calculation | ៤០ ០០០ | ៣-១០ ថ្ងៃ | |
| ១៨៣ | - សារធាតុខនិជផ្សេងទៀត | ២០០ ០០០ | ៣-១០ ថ្ងៃ | |
| | ១.៩ ទឹក និងទឹកកក (Water and Ices) | | | |
| ១៨៤ | - Arsenic by AAS | ៩០ ០០០ | ៣-១០ ថ្ងៃ | |
| ១៨៥ | - Bicarbonate | ៦០ ០០០ | ៣-១០ ថ្ងៃ | |
| ១៨៦ | - Chloride (as Sodium Chloride) | ៣០ ០០០ | ៣-១០ ថ្ងៃ | |
| ១៨៧ | - Conductivity | ២០ ០០០ | ៣-១០ ថ្ងៃ | |
| ១៨៨ | - Copper by AAS | ៤០ ០០០ | ៣-១០ ថ្ងៃ | |
| ១៨៩ | - Iron by AAS | ៤០ ០០០ | ៣-១០ ថ្ងៃ | |
| ១៩០ | - Manganese by AAS | ៤០ ០០០ | ៣-១០ ថ្ងៃ | |
| ១៩១ | - Nitrate | ៤០ ០០០ | ៣-១០ ថ្ងៃ | |
| ១៩២ | - pH-Value | ២០ ០០០ | ៣-១០ ថ្ងៃ | |
| ១៩៣ | - Sulfate | ៣០ ០០០ | ៣-១០ ថ្ងៃ | |
| ១៩៤ | - Total Disolved Solids (TDS) | ២០ ០០០ | ៣-១០ ថ្ងៃ | |
| ១៩៥ | - Total Hardness (as Calcium Cambonate) | ៣០ ០០០ | ៣-១០ ថ្ងៃ | |
| | ១.១០ ចំណាត់ថ្នាក់គ្រាប់ធញ្ញជាតិតាមប្រភេទ (Grading Specifications for Cereals) | | | |
| ១៩៦ | - Rice Specification | ២០០ ០០០ | ៣-១០ ថ្ងៃ | |

| លេខរៀងសេវា | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ១៩៧ | - Purity of Fragrant Rice | ១៦០ ០០០ | ៣-១០ ថ្ងៃ | |
| ១៩៨ | - Other Cereals | ២០០ ០០០ | ៣-១០ ថ្ងៃ | |
| | ២ មីក្រូសរីរាង្គក្នុងម្ហូបអាហារ (Microorganisms in Food) | | | |
| ១៩៩ | - Aerobic Plate Count / Total Plate Count | ៤០ ០០០ | ៣-១០ ថ្ងៃ | |
| ២០០ | - Bacillus cereus | ៨០ ០០០ | ៣-១០ ថ្ងៃ | |
| ២០១ | - Clostridum Perfringens | ១១០ ០០០ | ៣-១០ ថ្ងៃ | |
| ២០២ | - Total Coliforms, MPN | ៦០ ០០០ | ៣-១០ ថ្ងៃ | |
| ២០៣ | - Total Coliforms, Plate Count | ៨០ ០០០ | ៣-១០ ថ្ងៃ | |
| ២០៤ | - E.Coli, MPN | ៧០ ០០០ | ៣-១០ ថ្ងៃ | |
| ២០៥ | - Faecal Coliforms, MPN | ៨០ ០០០ | ៣-១០ ថ្ងៃ | |
| ២០៦ | - Listeria monocytogenes | ១០០ ០០០ | ៣-១០ ថ្ងៃ | |
| ២០៧ | - Salmonmella spp | ១២០ ០០០ | ៣-១០ ថ្ងៃ | |
| ២០៨ | - Staphylococcus aureus | ១០០ ០០០ | ៣-១០ ថ្ងៃ | |
| ២០៩ | - Vibrio Cholerae | ១០០ ០០០ | ៣-១០ ថ្ងៃ | |
| ២១០ | - E.Coli and Coliform in Water | ៨០ ០០០ | ៣-១០ ថ្ងៃ | |
| ២១១ | - Coagulase-Positive Staphylococci | ៨០ ០០០ | ៣-១០ ថ្ងៃ | |
| ២១២ | - Yeasts and Molds | ៦០ ០០០ | ៣-១០ ថ្ងៃ | |

| លេខរៀងសេវា | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ២១៣ | - β-Glucuronidase-positive E.coli | ៨០ ០០០ | ៣-១០ថ្ងៃ | |
| ២១៤ | - Enterobacteriaceae | ៩០ ០០០ | ៣-១០ថ្ងៃ | |
| | ៣ សំណល់សារធាតុពុលគីមីក្នុងម្ហូបអាហារ | | | |
| ២១៥ | - Pesticide Residues in Fresh Fruit and Vegetables by Test Kit | ៨០ ០០០ | ៣-១០ថ្ងៃ | |
| ២១៦ | - Pesticide Residues in Fresh Fruit and Vegetables by GC-MS/LC | ៣០០ ០០០ | ៣-១០ថ្ងៃ | |
| ២១៧ | - Polycyclic Aromatic Hydrocarbons (PAHs) by Test Kits | ៥០ ០០០ | ៣-១០ថ្ងៃ | |
| ២១៨ | - Polycyclic Aromatic Hydrocarbons (PAHs) by GC-MS | ៣០០ ០០០ | ៣-១០ថ្ងៃ | |
| ២១៩ | - Polychlorinated Biphenyl (PCBs) | ៣០០ ០០០ | ៣-១០ថ្ងៃ | |
| ២២០ | - 3-MCPD in Food by GC-MS | ៣០០ ០០០ | ៣-១០ថ្ងៃ | |
| ២២១ | - Micotoxins by HPLC | ៣០០ ០០០ | ៣-១០ថ្ងៃ | |
| | ៤ យថាប្រភេទគុណភាពប្រេងឥន្ធនៈ (Fuel Specifications) | | | |
| ២២២ | - Gasoline | ២១០ ០០០ | ៣-១០ ថ្ងៃ | |
| ២២៣ | - Diesel | ២៣០ ០០០ | ៣-១០ ថ្ងៃ | |
| ២២៤ | - Kerosene | ១៩០ ០០០ | ៣-១០ ថ្ងៃ | |
| ២២៥ | - JET A1 | ១៩០ ០០០ | ៣-១០ ថ្ងៃ | |
| ២២៦ | - Fuel Oil | ១៩០ ០០០ | ៣-១០ ថ្ងៃ | |
| ២២៧ | - Engine Oil | ២៥០ ០០០ | ៣-១០ ថ្ងៃ | |
| ២២៨ | - Base Oil | ២៥០ ០០០ | ៣-១០ ថ្ងៃ | |

| លេខរៀងសេវា | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្ដល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ២២៩ | - Sulfur in Fuel | ២០០ ០០០ | ៣-១០ថ្ងៃ | |
| ២៣០ | - Octane Index RON/MON | ១៥០ ០០០ | ៣-១០ថ្ងៃ | |
| ២៣១ | - Distillation of Petroleum Products | ១៥០ ០០០ | ៣-១០ថ្ងៃ | |
| ២៣២ | - Aromatics in Gasolines | ១២០ ០០០ | ៣-១០ថ្ងៃ | |
| | ៥ ផលិតផលប្រើប្រាស់ (Consumer Products) | | | |
| ២៣៣ | - Asbestos | ១២០ ០០០ | ៣-១០ថ្ងៃ | |
| ២៣៤ | - Heavy Metals in Toys by XRF | ៦០ ០០០ | ៣-១០ថ្ងៃ | |
| ២៣៥ | - Heavy Metals in Cosmetics by XRF | ៦០ ០០០ | ៣-១០ថ្ងៃ | |
| ២៣៦ | - Parabens in Cosmetics by LC | ១២០ ០០០ | ៣-១០ថ្ងៃ | |
| ២៣៧ | - Hydroquinone by LC | ១២០ ០០០ | ៣-១០ថ្ងៃ | |
| | ៦ យថាប្រភេទផលិតផលគីមី (Specifications for Chemicals) | | | |
| ២៣៨ | - Test for Purity of Acids | ២១០ ០០០ | ៣-១០ ថ្ងៃ | |
| ២៣៩ | - Test for Purity of Organic Solvents | ១៦០ ០០០ | ៣-១០ ថ្ងៃ | |
| ២៤០ | - Test for Purity of Salts | ១១០ ០០០ | ៣-១០ ថ្ងៃ | |
| ២៤១ | - Test for Purity of Fertilizers | ២១០ ០០០ | ៣-១០ ថ្ងៃ | |
| ២៤២ | - Test for Purity of Food Additives | ២១០ ០០០ | ៣-១០ ថ្ងៃ | |

| លេខរៀងសេវា | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ២៤៣ | ៧ ការវិភាគផ្សេងៗ ដែលមិនមានក្នុងតារាងខាងលើ (Other analysis parameters not specified above) | កំណត់ដោយមន្ទីរពិសោធន៍ ដែលទទួលវិភាគ + ៥០ ០០០ | ៣-១០ ថ្ងៃ | |
| | ខ. សេវាយកគំរូផលិតផល ទំនិញនៅតាមបណ្តាខេត្ត-រាជធានី | | | |
| ២៤៤ | - ចម្ងាយផ្លូវយ៉ាងច្រើនត្រឹម ១០០គ.ម | ៣០០ ០០០ | ១ ថ្ងៃ | |
| ២៤៥ | - ចម្ងាយផ្លូវលើសពី ១០០គ.ម ទៅ ២០០គ.ម | ៣៨០ ០០០ | ១ ថ្ងៃ | |
| ២៤៦ | - ចម្ងាយផ្លូវលើសពី ២០១គ.ម ឡើងទៅ | ៥០០ ០០០ | ១ ថ្ងៃ | |
| | **នាយកដ្ឋានកិច្ចការការពារអ្នកប្រើប្រាស់ និងបង្ក្រាបការក្លែងបន្លំ** | | | |
| | ក. ត្រួតពិនិត្យជាលក្ខណៈពាណិជ្ជកម្មភាគីទី៣ តាមការស្នើសុំរបស់អតិថិជន | | | |
| | ១ ការត្រួតពិនិត្យ និងចេញរបាយការណ៍បញ្ជាក់លើបរិមាណ ឬ ទម្ងន់ ក្នុង១ប្រភេទមុខទំនិញ | | | |
| ២៤៧ | - តិចជាង ១តោន | ២០០ ០០០ | ១-១០ថ្ងៃ | |
| ២៤៨ | - ចាប់ពី ១តោន ទៅដល់១០តោន | ៤០០ ០០០ | ១-១០ថ្ងៃ | |
| ២៤៩ | - ចាប់ពី ១០តោន ទៅដល់១០០តោន | ៨០០ ០០០ | ១-១០ថ្ងៃ | |
| ២៥០ | - ចាប់ពី ១០០តោន | ២ ០០០ ០០០ | ១-១០ថ្ងៃ | |
| | ២ ការត្រួតពិនិត្យបញ្ជាក់អំពីទំនិញខូចគុណភាព | | | |
| ២៥១ | - ត្រួតពិនិត្យ និងចេញរបាយការណ៍បញ្ជាក់ពីស្ថានភាពទំនិញ | ៤០០ ០០០ | ១-១០ថ្ងៃ | |
| ២៥២ | - ត្រួតពិនិត្យ និងចេញរបាយការណ៍បញ្ជាក់ពីទំនិញបាក់បែក ឬខូច (Damaged cargoes) | ៨០០ ០០០ | ១-១០ថ្ងៃ | |
| ២៥៣ | - ត្រួតពិនិត្យ និងចេញរបាយការណ៍កំទិចចោល (Spoiled Food) | ៤០០ ០០០ | ១-១០ថ្ងៃ | |

| លេខរៀងសេវា | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| | ខ. សេវាត្រួតពិនិត្យទំនិញនាំចេញ នាំចូល | | | |
| | ១ ទំនិញទូទៅ | | | |
| | ១.១ ទំនិញដឹកជញ្ជូនតាមផ្លូវទឹក | | | |
| | + កុងទែន័រ : | | | |
| ២៥៤ | - កុងទែន័រពេញទី១ | ២៥០ ០០០ | ១ ថ្ងៃ | |
| ២៥៥ | - កុងទែន័រពេញទី២ និងបន្តបន្ទាប់ | ១៥០ ០០០ | ១ ថ្ងៃ | |
| ២៥៦ | - កុងទែន័រមិនពេញ | ១៥០ ០០០ | ១ ថ្ងៃ | |
| | + ឃ្លប់នាវា : | | | |
| ២៥៧ | - ឃ្លប់ទី១ | ៤០០ ០០០ | ១ ថ្ងៃ | |
| ២៥៨ | - ឃ្លប់ទី២ និងបន្តបន្ទាប់ | ២០០ ០០០ | ១ ថ្ងៃ | |
| ២៥៩ | - ការងារត្រួតពិនិត្យក្នុង ១shipment | ១៦០ ០០០ | ១ ថ្ងៃ | |
| | + ផ្ទុកតាមទូក : | | | |
| ២៦០ | - ទូកមានចំណុះច្រើនជាង ២០តោន | ២៥០ ០០០ | ១ ថ្ងៃ | |
| ២៦១ | - ទូកមានចំណុះតិចជាង ឬស្មើ ២០តោន | ១៣០ ០០០ | ១ ថ្ងៃ | |
| | ១.២ ទំនិញដឹកជញ្ជូនតាមផ្លូវគោក | | | |
| | + កុងទែន័រ : | | | |
| ២៦២ | - កុងទែន័រពេញទី១ | ២៥០ ០០០ | ១ ថ្ងៃ | |
| ២៦៣ | - កុងទែន័រពេញទី២ និងបន្តបន្ទាប់ | ១៥០ ០០០ | ១ ថ្ងៃ | |

| លេខរៀងសេវា | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ២៦៤ | - កុងតែន័រមិនពេញ | ១៥០ ០០០ | ១ ថ្ងៃ | |
| | + ផ្ទុកតាមរថយន្ត : | | | |
| ២៦៥ | - ចំណុះលើសពី ១០តោន | ១១០ ០០០ | ១ ថ្ងៃ | |
| ២៦៦ | - ចំណុះតិចជាង ឬស្មើ ១០តោន | ៩០ ០០០ | ១ ថ្ងៃ | |
| | ១.៣ ទំនិញដឹកជញ្ជូនតាមយន្តហោះ | | | |
| | + ប៉ាឡែត : | | | |
| ២៦៧ | - ប៉ាឡែតទី១ | ១៦០ ០០០ | ១ ថ្ងៃ | |
| ២៦៨ | - ប៉ាឡែតទី២ និងបន្តបន្ទាប់ | ៨០ ០០០ | ១ ថ្ងៃ | |
| ២៦៩ | - ការងារត្រួតពិនិត្យក្នុង១ឯកសារ | ៤០ ០០០ | ១ ថ្ងៃ | |
| | + ទំនិញជាកញ្ចប់រាយ : | | | |
| ២៧០ | - បរិមាណច្រើនជាង ០៥កញ្ចប់ | ៨០ ០០០ | ១ ថ្ងៃ | |
| ២៧១ | - បរិមាណតិចជាង ឬស្មើ ០៥កញ្ចប់ | ៦០ ០០០ | ១ ថ្ងៃ | |
| ២៧២ | - ការងារត្រួតពិនិត្យក្នុង ១ឯកសារ | ៤០ ០០០ | ១ ថ្ងៃ | |
| | ២ ទំនិញរាវ | | | |
| | + ផ្ទុកក្នុងនាវា : | | | |
| ២៧៣ | - ទំនិញរាវដាក់នៅក្នុងឃ្លប់ទី១ | ១៦០ ០០០ | ១ ថ្ងៃ | |
| ២៧៤ | - ទំនិញរាវដាក់នៅក្នុងឃ្លប់ចាប់ពីឃ្លប់ទី២ និងបន្តបន្ទាប់ | ៨០ ០០០ | ១ ថ្ងៃ | |
| ២៧៥ | - ការងារត្រួតពិនិត្យក្នុង ១shipment | ១៦០ ០០០ | ១ ថ្ងៃ | |

| លេខរៀងសេវា | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| | + ផ្ទុកក្នុងរថយន្ត (ស៊ីទែន) : | | | |
| ២៧៦ | - ទំនិញរាវដាក់នៅក្នុងស៊ីទែនទី១ | ១២០ ០០០ | ១ ថ្ងៃ | |
| ២៧៧ | - ទំនិញរាវដាក់នៅក្នុងស៊ីទែនទី២ និងបន្តបន្ទាប់ | ៨០ ០០០ | ១ ថ្ងៃ | |
| | ៣ ទំនិញជាវត្ថុធាតុដើមសម្លៀកបំពាក់ និងវាយនភណ្ឌ | | | |
| | ៣.១ ទំនិញដឹកជញ្ជូនតាមផ្លូវទឹក | | | |
| ២៧៨ | - កុងទែន័រពេញទី១ | ២៥០ ០០០ | ១ ថ្ងៃ | |
| ២៧៩ | - កុងទែន័រពេញទី២ និងបន្តបន្ទាប់ | ១៥០ ០០០ | ១ ថ្ងៃ | |
| ២៨០ | - កុងទែន័រមិនពេញ | ១៥០ ០០០ | ១ ថ្ងៃ | |
| | ៣.២ ទំនិញដឹកជញ្ជូនតាមផ្លូវគោក | | | |
| ២៨១ | - កុងទែន័រពេញទី១ | ២៥០ ០០០ | ១ ថ្ងៃ | |
| ២៨២ | - កុងទែន័រពេញទី២ និងបន្តបន្ទាប់ | ១៥០ ០០០ | ១ ថ្ងៃ | |
| ២៨៣ | - កុងទែន័រមិនពេញ | ១៥០ ០០០ | ១ ថ្ងៃ | |
| | ៤ ទំនិញពាក់កណ្តាលកែច្នៃពីកសិផល | | | |
| ២៨៤ | - កុងទែន័រពេញទី១ | ១៥០ ០០០ | ១ ថ្ងៃ | |
| ២៨៥ | - កុងទែន័រពេញទី២ និងបន្តបន្ទាប់ | ១០០ ០០០ | ១ ថ្ងៃ | |
| ២៨៦ | - កុងទែន័រមិនពេញ | ១០០ ០០០ | ១ ថ្ងៃ | |
| ២៨៧ | ៥ ទំនិញជាផលិតផលកសិកម្មទូទៅ (គិតក្នុង ១ឯកតា) | ១៥ ០០០ | ១ ថ្ងៃ | |

| លេខរៀងសេវា | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ២៨៨ | ៦ ទំនិញជាអង្ករ (គិតក្នុង ១shipment) | មិនគិតថ្លៃ | ១ ថ្ងៃ | |
| ២៨៩ | ៧ ទំនិញទូទៅដោះដូរតាមព្រំដែន តាមរបៀង និងមធ្យោបាយសាមញ្ញ | ២៥ ០០០ | ១ ថ្ងៃ | |
| ២៩០ | គ. ការចេញសេចក្តីបញ្ជាក់លើការពិនិត្យសំណុំឯកសារនាំចូល(គិត ១ ឯកសារ) | ៦០ ០០០ | ១ | ១ ខែ |
| | - បញ្ជាក់នូវកម្រិតហានិភ័យនៃប្រភេទផលិតផលពាក់ព័ន្ធនឹងជើងបញ្ជូនទំនិញ | | | |
| | - បង្ហាញប្រព្រឹត្តកម្មជាក់លាក់សម្រាប់ការត្រួតពិនិត្យនៅច្រកចេញ-ចូល | | | |